ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៣៧៥.ព្រទ-៩៦

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោកប្រធានតុលាការខេត្តកំពត**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីការឃុំខ្លួនជនល្មើសដែលចាប់ខ្លួនបានក្រោយពេលជំនុំជម្រះកំបាំងមុខ ។
**<u>យោង:</u>** លិខិតលេខ ៣៣៨ រប-៩៦ ចុះថ្ងៃទី១៦-០៧-៩៦ របស់តុលាការខេត្តកំពត ។

ខ្ញុំសូមជម្រាបលោកថា ចំពោះករណីជនល្មើសដែលបានរត់គេចខ្លួន ប៉ុន្តែចៅក្រមស៊ើបអង្កេតបានចេញដីកាស្វែងរកចាប់ខ្លួនរួចហើយៗ បន្តការស៊ើបអង្កេតរបស់ខ្លួនចប់សព្វគ្រប់តាមនីតិវិធី រហូតដល់ជូនរឿងទៅជំនុំជម្រះចៅក្រមជំនុំជម្រះក៏បានដាក់សំណុំរឿងនេះជំនុំជម្រះ សម្រេចសេចក្តីកំបាំងមុខរួចហើយ ទើបមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួនជនល្មើសបានមកវិញនោះ តាមគោលការណ៍ច្បាប់ សំណុំរឿងដែលជំនុំជម្រះរួចហើយមិនអាចបង្វិលទៅឲ្យចៅក្រមស៊ើបសួរចាត់ការវិញបានឡើយ ដូច្នេះរឿងបែបនេះដើម្បីការពារការរត់គេចខ្លួនរបស់ជនល្មើសជាថ្មី គប្បីចាត់ការតាមគោលការណ៍ដូចខាងក្រោមនេះ ៖

តាមនីតិវិធីព្រហ្មទណ្ឌ ជនល្មើសដែលត្រូវចាប់បញ្ជូនមកតុលាការ គឺត្រូវបញ្ជូនតាមរយៈអយ្យការ ចំពោះករណីខាងលើនគរបាល ដែលចាប់បានជនល្មើសតាមអំណាចដីកាចាប់ខ្លួនរបស់ចៅក្រមស៊ើបអង្កេតហើយត្រូវបញ្ជូនទៅខាងអយ្យការ ព្រះរាជអាជ្ញាឬព្រះរាជអាជ្ញារងរួមជាមួយក្រឡាបញ្ជីមួយនាក់ ប្រគល់លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ ឱ្យជនល្មើសផ្តិតមេដៃទទួលរួចធ្វើកំណត់ហេតុសួរយកចម្លើយជនល្មើស ថាតើគេប្តឹងទាស់ឬប្តឹងឧទ្ធរណ៍នឹងសាលក្រមកំបាំងមុខនេះឬទេ? ទោះបីជនល្មើសប្តឹងក៏ដោយឬមិនប្តឹងក៏ដោយព្រះរាជអាជ្ញាត្រូវតែចាត់ក្រឡាបញ្ជីឱ្យសរសេរក្នុងកំណត់ហេតុសួរចម្លើយនោះឱ្យបានច្បាស់លាស់ រួចហើយឱ្យជនល្មើសផ្តិតមេដៃតាមរបៀបរបបធ្វើកំណត់ហេតុធម្មតា បន្ទាប់មកទើបបញ្ជូនទៅចៅក្រមដែលជំនុំជម្រះសំណុំរឿងនេះ ។ ចៅក្រមជំនុំជម្រះនៅពេលបានទទួលកំណត់ហេតុនិងជនល្មើស ត្រូវធ្វើសេចក្តីសម្រេចមុនអង្គសេចក្តីឃុំខ្លួនជនល្មើស រួចដាក់សេចក្តីសម្រេចនេះនិងកំណត់ហេតុ ចូលក្នុងសំណុំរឿងអង្គសេចក្តីដែលបានជំនុំជម្រះកំបាំងមុខនោះ រួចហើយទើបពិនិត្យនិងចាត់ចែងតាមនីតិវិធីអំពីបណ្តឹងទាស់ឬបណ្តឹងឧទ្ធរណ៍ បើសិនជាជនល្មើសប្តឹង ។

ផ្ទុយទៅវិញក្នុងករណីដែលចៅក្រមជំនុំជម្រះពុំទាន់បានជំនុំជម្រះសំណុំរឿងនោះនៅឡើយទេ ចៅក្រមជំនុំជម្រះអាចបង្វិលសំណុំរឿងឱ្យទៅចៅក្រមស៊ើបអង្កេត ដើម្បីពិនិត្យសម្រេចអំពីការឃុំខ្លួនជនល្មើសតាមដីកាចាប់ខ្លួននេះសិន ។

សូមលោកប្រធានអនុវត្តគោលការណ៍នេះ ដោះស្រាយរឿងក្តីដែលពាក់ព័ន្ធឱ្យមានប្រសិទ្ធិភាពខ្ពស់ និងត្រឹមត្រូវតាមច្បាប់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>
- តុលាការខេត្ត-ក្រុង
- អយ្យការអមតុលាការខេត្ត-ក្រុង
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- ដើម្បីជ្រាប និងអនុវត្ត